123 3 Feb/2021

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**តុលាការកំពូល**

**សភាព្រហ្មទណ្ឌ**

សំណុំរឿងព្រហ្មទណ្ឌ
លេខ ១៤០
ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២០
សាលដីកា
លេខ ៨៦ "II"
ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២១
ដោយអង្គជំនុំជម្រះមានសមាសភាពចៅក្រមដូចខាងក្រោម ៖

១. លោកជំទាវ [redacted] ជាប្រធាន
២. ឯកឧត្តម [redacted] ជាចៅក្រម
៣. ឯកឧត្តម [redacted] ជាចៅក្រម
៤. ឯកឧត្តម [redacted] ជាចៅក្រម
៥. លោកជំទាវ [redacted] ជាចៅក្រម

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

**តំណាងមហាអយ្យការ**

ឯកឧត្តម [redacted] ជាព្រះរាជអាជ្ញា

**ដើម្បីជំនុំជម្រះ**

លើបណ្តឹងសាទុក្ខលេខ ៨២ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] និងបណ្តឹងសាទុក្ខលេខ ៨៥ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] សុជាតិ ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ២៨ ក្រVសស ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០ របស់សភាព្រហ្មទណ្ឌ សាលាឧទ្ធរណ៍ភ្នំពេញដែលមាន ៖

១-ជនជាប់ចោទឈ្មោះ [redacted]ុជាតិ ភេទប្រុស អាយុ ៣៥ឆ្នាំ ជនជាតិខ្មែរ មុខរបរបើកបរថយន្តតាក់ស៊ី មានទីកន្លែងកំណើត និងលំនៅឋានមុនពេលឃុំខ្លួននៅ [redacted] ស្រុក[illegible] ខេត្តស្វាយរៀង ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] មានកូន[illegible]នាក់ ទោសពីមុនគ្មាន។ ឃុំខ្លួនថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧ (ពន្ធនាគារខេត្តស្វាយរៀង)។ (អ្នកប្តឹងសាទុក្ខ)



Scanned with CamScanner

-មានលោក[redacted] សំអាត និងលោ[redacted]ាន់ ជាមេធាវីការពារសិទ្ធិ។

២-ជនជាប់ចោទឈ្មោះ[redacted] សូនី ភេទប្រុស អាយុ ៣២ឆ្នាំ ជនជាតិខ្មែរ មុខរបរបើករថយន្តតាក់ស៊ី មានទីកន្លែងកំណើត និងលំនៅឋានមុនពេលឃុំ[redacted] ស្រុកកំពង់ពោធិ៍ ខេត្តស្វាយរៀង ឪពុកឈ្មោះ[redacted] ម្តាយឈ្មោះ[redacted] ប្រពន្ធឈ្មោះ[redacted] មានកូន ០២នាក់ ទោសពីមុនគ្មាន។ ឃុំខ្លួនថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧ (ពន្ធនាគារខេត្តស្វាយរៀង)។ (អ្នកប្តឹងសាទុក្ខ)

-មានលោក[redacted] សម្បត្តិ ជាមេធាវីការពារសិទ្ធិ។

-ជាប់ចោទពីបទៈ ឃាតកម្មដោយមានទារុណកម្ម និងអំពើរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិតាពៅ សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង កាលពីថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២០៥ នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] ស្រីឡូត ភេទស្រី អាយុ ៣៥ឆ្នាំ និងប្តីឈ្មោះ[redacted] សុវណ្ណ អាយុ ៣៨ឆ្នាំ ជនជាតិខ្មែរ មុខរបរធ្វើស្រែ មានទីលំនៅសព្វថ្ងៃនៅភូមិដូនម៉ៅលើ ឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។

-មានលោកស្រី[redacted] ស៊ីណាកេត ជាមេធាវីការពារ។

## អំពីអង្គហេតុ

កាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០១៨ សមត្ថកិច្ចជំនាញនគរបាលព្រហ្មទណ្ឌខេត្តស្វាយរៀង បានទទួលពាក្យបណ្តឹងពីឈ្មោះ[redacted] សុវណ្ណ ប្តឹងឱ្យសមត្ថកិច្ចជួយស្រាវជ្រាវកូនស្រីខ្លួនឈ្មោះ[redacted] សុម៉ាលីន ដែលបានបាត់ខ្លួនកាលពីថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៧ នៅពេលដែលកូនស្រីខ្លួនត្រឡប់មកពីផ្ទះនៅខេត្តព្រះវិហារមកធ្វើការនៅខេត្តស្វាយរៀងវិញ នៅពេលមកដល់ចំណុចផ្សារដើភូក៏បាត់ដំណឹង។ ក្រោយទទួលបានពាក្យបណ្តឹង សមត្ថកិច្ចបានធ្វើការស្រាវជ្រាវកំណត់មុខសញ្ញា និងឈានទៅដល់ការឃាត់ខ្លួនជនសង្ស័យឈ្មោះ[redacted] សុជាតិ ដើម្បីធ្វើការសាកសួរនៅចំពោះមុខសមត្ថកិច្ចឈ្មោះ[redacted] សុជាតិ បានឆ្លើយសារភាពថា ខ្លួនពិតជាបានប្រព្រឹត្តអំពើរំលោភសម្លាប់នារីរងគ្រោះនៅចំណុចភូមិតាពៅ សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង កាលពីថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៧ នោះពិតមែន ដោយសកម្មភាពជាមួយបក្ខពួកម្នាក់ទៀតឈ្មោះ[redacted] សូនី ជាអ្នករត់តាក់ស៊ីដូចគ្នា។ ក្នុងពេលនោះសមត្ថកិច្ចក៏បានធ្វើការឆែកឆេរក្នុងរថយន្តម៉ាកហាយលែនឌ័រពណ៌សជារបស់ឈ្មោះ[redacted] សុជាតិ រកឃើញខ្សែក កាំខ្សែចំនួន ០១... ចិញ្ចៀនដាំត្បូងពណ៌សកាខ្សែ ០១វង់ របស់ជនរងគ្រោះនៅក្នុងរថយន្តទៀតផង។ នៅក្នុងថ្ងៃដដែលនោះដែរ

Scanned with CamScanner

មានកិច្ចសហការជាមួយកំលាំងជំនាញនគរបាលព្រហ្មទណ្ឌកំរិតធ្ងន់ នៃនាយកដ្ឋាននគរបាលព្រហ្មទណ្ឌ ក៏បានឃាត់ខ្លួនជនសង្ស័យដែលជាបក្ខពួកម្នាក់ទៀតឈ្មោះ[redacted]សូនី នាំមកសាកសួរ និងកសាងសំណុំរឿងបញ្ជូនមកអយ្យការចាត់ការតាមច្បាប់។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ២០០ (យ) ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តស្វាយរៀង ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ផ្តន្ទាទោសលើ

ក.ឈ្មោះ[redacted] សុជាតិ ភេទប្រុស អាយុ ៣៥ឆ្នាំ

ខ.ឈ្មោះ[redacted] សូនី (ហៅមុន្នី) ភេទប្រុស អាយុ ៣២ឆ្នាំ ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់អស់មួយជីវិត ពីបទ៖ ឃាតកម្មដោយមានមារុណកម្ម និងអំពើរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិតាពៅ សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង កាលពីថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២០៥ នៃក្រមព្រហ្មទណ្ឌ។

២-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ[redacted] សុជាតិ និងឈ្មោះ[redacted]សូនី ហៅ មុន្នី រួមគ្នាសងប្រាក់សំណងទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]សុវណ្ណ ចំនួន ៦០.០០០ (ប្រាំមួយម៉ឺន)ដុល្លារអាមេរិក។

៣-វត្ថុតាងរួមមាន៖

-រថយន្តម៉ាកហាយលែនឌ័រពណ៌ស ពាក់ស្លាកលេខភ្នំពេញ 2AQ-0525 និងទូរស័ព្ទដៃចំនួន ០៤ គ្រឿង ដែលបានដកហូតពីជនជាប់ចោទត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ។

-រថយន្តម៉ាក Lexus RX300 ពណ៌ទឹកមាស ពាក់ស្លាកលេខភ្នំពេញ 2AL-4238 ផលិតក្នុងឆ្នាំ ២០០០ ដែលមានលេខម៉ាស៊ីន 1MZ 1396838 និងលេខតួ JT6HF 10U7Y0102473 និងចង្កឹះសោរចំនួន១ ត្រូវប្រគល់ឱ្យទៅម្ចាស់ដើមប្រើប្រាស់ជាកម្មសិទ្ធិវិញ។

-ខ្សែកកាឡៃ ១ខ្សែ ចិញ្ចៀនកាឡៃ ១វង់ មានដាំត្បូងពណ៌សត្រូវប្រគល់ឱ្យទៅឈ្មោះ[redacted]ស្រីឡូត ដែលត្រូវជាម្តាយសពជនរងគ្រោះវិញ។

-ខ្សែដៃប្លាកទីន ១ខ្សែទម្ងន់ ៣៨៣លី (ទឹក៧), ចិញ្ចៀនត្រាមាស ១វង់ ទម្ងន់ ៣ជី (មានស៩៩៩), វ៉ាលីដាក់ខោអាវពណ៌ក្រហម១, អត្តសញ្ញាប័ណ្ណសញ្ជាតិខ្មែរ១ ([redacted]សូនី) ត្រូវប្រគល់ឱ្យទៅម្ចាស់ដើមវិញ។

៤-សាលក្រមនេះជំនុំជម្រះ និងប្រកាសសាលក្រមជាស្ថាពរ ចំពោះមុខជនជាប់ចោទឈ្មោះ[redacted]សុជាតិ, ឈ្មោះ[redacted]សូនី និងដើមបណ្តឹងរដ្ឋប្បវេណី។

-បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។



Scanned with CamScanner

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ៤២ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨ របស់ជនជាប់ចោទ ឈ្មោះ [redacted] សុជាតិ ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ២០០ (ឃ) ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តស្វាយរៀងត្រង់ចំណុចទី១(ក), ទី២ និងទី៣ នៃសេចក្តីសម្រេចទាំងមូល។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ៤៣ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨ របស់ជនជាប់ចោទ ឈ្មោះ [redacted] សូនី ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ២០០ (ឃ) ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តស្វាយរៀងត្រង់ចំណុចទី១(ខ) និងទី២ នៃសេចក្តីសម្រេចទាំងមូល។

-បានឃើញ សាលដីកាលេខ ២៨ ក្រVសស ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍លេខ ៤២ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] សុជាតិ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

២-ទទួលពាក្យបណ្តឹងឧទ្ធរណ៍លេខ ៤៣ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] សូនី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

៣-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២០០ (ឃ) ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តស្វាយរៀង ទុកជាបានការទាំងមូលដដែល។

៤-បន្តការឃុំខ្លួនជនជាប់ចោទតាមនីតិវិធីច្បាប់។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈនៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០ កំបាំងមុខជនជាប់ចោទ តែចាត់ទុកជាចំពោះមុខ និងចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីណ បើផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់។

-បានឃើញ បណ្តឹងសាទុក្ខលេខ ៨២ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោ[redacted] សូនី ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ២៨ ក្រVសស ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញ បណ្តឹងសាទុក្ខលេខ ៨៥ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] សុជាតិ ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ២៨ ក្រVសស ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។



Scanned with CamScanner

## នាពេលសវនាការ

-ចៅក្រមរបាយការណ៍បានអានរបាយការណ៍

-តំណាងមហាអយ្យការអមតុលាការកំពូល បានធ្វើសេចក្ដីសន្និដ្ឋានថា ជនជាប់ចោទ [redacted]សុជាតិ បានឆ្លើយសារភាពដោយបញ្ជាក់ថា បានរំលោភសេពសន្ថវៈ និងឃាតកម្មលើជនរងគ្រោះ ដូចការរកឃើញរបស់តុលាការអង្គសេចក្ដីប្រាកដមែន។ ជនជាប់ចោទ [redacted]សុជាតិ បានបញ្ជាក់ថា [redacted]សូនី ជាអ្នកចងដៃរំលោភសេពសន្ថវៈលើជនរងគ្រោះមុន រួចហើយ សុជាតិ រំលោភជនរងគ្រោះតាមក្រោយ រួចយកកន្សែងចងកជនរងគ្រោះកន្ត្រាក់ចុះពីឡាន ហើយអូសជនរងគ្រោះទៅទម្លាក់ក្នុងទឹក យកថ្មសង្កត់ពីលើក្បាល។ ម្យ៉ាងវិញទៀតរថយន្តហាយលែនឌ័រ គឺជាវត្ថុតាងក្នុងការប្រើប្រាស់ក្នុងសកម្មភាពប្រព្រឹត្តបទល្មើសពិតប្រាកដ។ កំណត់ហេតុស្រាវជ្រាវ និងពិនិត្យកន្លែងកើតហេតុលេខ ១១/១៧ ក.ហ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៧ របស់សមត្ថកិច្ចជំនាញ អះអាងបញ្ជាក់ថា ជនរងគ្រោះស្លាប់ដោយសារអំពើរំលោភសេពសន្ថវៈ និងសម្លាប់ កាលពីថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៧ និងបានប្រគល់សពឱ្យទៅក្រុមគ្រួសារយកទៅធ្វើបុណ្យតាមប្រពៃណី។ ចម្លើយដោះសាររបស់ជនជាប់ចោទ [redacted] សូនី មិនអាចឱ្យតុលាការជឿទុកចិត្តបានទេ ព្រោះគ្មានភស្តុតាងដោះបន្ទុកគ្រប់គ្រាន់។ តាមអង្គហេតុបានកើតឡើង គឺមានភាពស៊ីសង្វាក់គ្នាជាមួយចម្លើយរបស់សាក្សីជាច្រើន ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងភស្តុតាងដែលសមត្ថកិច្ចជំនាញប្រមូលយកបាន។ ជនជាប់ចោទទាំងពីរខាងលើពិតជាបានទាក់ទងគ្នា និងមានចេតនាទុច្ចរិតប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់របស់តុលាការអង្គសេចក្ដីមែន។ តាមចម្លើយរបស់សាក្សីខ្លះ ដែលបានឆ្លើយជួយដោះបន្ទុកជនជាប់ចោទ គឺមិនមានមូលដ្ឋានឱ្យជឿជាក់បានទេ។ ចំពោះកម្រិតទោសត្រូវផ្ដន្ទាទោស គឺមានកម្រិតធ្ងន់សមស្របទៅតាមបទល្មើសហើយ ដោយសារជនជាប់ចោទបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌច្រើនដែលជាបទឧក្រិដ្ឋដូចបញ្ជាក់ខាងលើ។ តាមសំអាងហេតុដែលបានលើឡើងដោយសាលាដំបូង និងសាលាឧទ្ធរណ៍ភ្នំពេញមានសំអាងហេតុច្បាស់លាស់គ្រប់គ្រាន់ និងសមស្របតាមបញ្ញត្តិច្បាប់ហើយ។ ហេតុដូច្នេះតំណាងមហាអយ្យការអមតុលាការកំពូលប្ដឹងសុំឱ្យតម្កល់សាលដីកាព្រហ្មទណ្ឌលេខ ២៨ ក្រVសស ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញទុកជាបានការដដែល។

-ជនជាប់ចោទឈ្មោះ [redacted] សុជាតិ បានឆ្លើយថាខ្លួនសុំសំណូមពរឱ្យតុលាការជួយបន្ធូរបន្ថយទោស និងបន្ថយសំណងឱ្យខ្លួនផង ពីព្រោះវាច្រើនពេក។ នៅថ្ងៃកើតហេតុខ្លួនជាអ្នករត់តាក់ស៊ីបានចាប់ម៉ូយពីអូឡាំពិចទៅស្វាយរៀង ដែលមានម៉ូយទាំងអស់ចំនួន ៧នាក់ ហើយខ្លួនបានចេញដំណើរទៅជាមួយគ្នាជាមួយ [redacted]សូនី នៅអ្នកលឿងត្រើយខាងលិច ហើយ[redacted] សូនី បានសួរខ្លួនថាមានម៉ូយប៉ុន្មាននាក់ ហើយមានស្រីស្អាតអត់ ហើយខ្លួនក៏បានឆ្លើយថាហេន ហើយ[redacted]សូនី បានប្រាប់ខ្លួនថាគេទៅចាំនៅផ្សារ[illegible] នៅ

ពេលទៅដល់នោះខ្លួនបានដាក់ម៉ូយចុះអស់ នៅសល់តែនារីរងគ្រោះនោះម្នាក់ឯងទេ ហើយ[redacted] សូនី នៅក្បែរៗនោះ ក៏បានឡើងលើឡានរបស់ខ្លួននៅបាំងក្រោយ ហើយខ្លួនក៏បានធ្វើដំណើរបន្តទៀតទៅសសរថ្ម ថាទៅយកម៉ូយម្នាក់ទៀត ប៉ុន្តែដោយសារតែគេទៅម៉ូយមិនចូល ដែលនៅពេលម៉ោងប្រហែល ៦ ល្ងាចហើយ ខ្លួនក៏ចេះតែបន្តទៅទៀត ហើយពេលនោះនារីរងគ្រោះបានសួរខ្លួនថា "ពូកំពុងតែជិះទៅណាហ្នឹង" ហើយខ្លួនបានប្រាប់នារីរងគ្រោះថាកំពុងជិះទៅផ្លូវបាវិតហើយ ពេលនោះផ្លូវរលាក់ និងមានភ្លៀងរលឹមៗ [redacted] សូនី នៅបាំងក្រោយក៏បានចាប់ផ្តើមធ្វើសកម្មភាពប្រតាយប្រតប់គ្នា ក៏ចាប់ចងដៃនារីរងគ្រោះទៅក្រោយ និងបានចាប់សង្កត់នារីរងគ្រោះរំលោភនៅលើឡានរហូតដល់សន្លប់រួចហើយ ពេលនោះនៅតាមផ្លូវមិនសូវមានមនុស្សទេ ពេលមកដល់ផ្លូវកែងចូលរោងចក្រយើង ខ្លួនក៏បានឈប់ឡាន[redacted]សូនី បានចុះពីឡាន ខ្លួនក៏បានទៅរំលោភនារីរងគ្រោះម្តងពេលនារីរងគ្រោះសន្លប់ហើយ។ ក្រោយម[redacted]សូនី ក៏បានទៅយកកន្សែងទៅទាក់កនារីរងគ្រោះយកទៅទម្លាក់ទឹក ពេលនោះខ្លួនគឺមិនបានចាបអារម្មណ៍ថា [redacted]សូនី បានដាក់ថ្មសង្កត់ឬអត់នោះទេ។ ហើយខ្លួនបានហៅ [redacted] សូនី ឱ្យឡើងឡាន ដើម្បីធ្វើដំណើរមកផ្ទះវិញ។ មួយវិញទៀតពីមុនមកខ្លួនធ្លាប់បានធ្វើសកម្មភាពបែបនេះចំនួន ២ដងហើយជាមួយ [redacted]សូនី ដោយ[redacted]សូនី បានរំលោភស្ត្រីជនជាតិវៀតណាមកាលពី ៣-៤ ឆ្នាំមុន។ ជាចុងក្រោយខ្លួនសំណូមពរសុំឱ្យតុលាការបន្ធូរបន្ថយទោសសមរម្យតាមតុលាការសម្រេចចុះ។

-ជនជាប់ចោទឈ្មោះ[redacted]សូនី បានឆ្លើយថា ខ្លួនសុំឱ្យតុលាការជួយរកយុត្តិធម៌ឱ្យខ្លួនផង ពីព្រោះខ្លួនមិនបានធ្វើរឿងនេះទេ។ នៅថ្ងៃកើតហេតុគឺខ្លួនបានដឹកម៉ូយពីព្រលានទៅផ្ទះ ហើយម៉ោង ៦ គឺខ្លួននៅផ្ទះ។ ខ្លួនមិនបានជិះឡានជាមួយ [redacted] សុជាតិ ទេ គឺខ្លួនមានម៉ូយជនជាតិចិនដែលត្រូវដឹកដែរ។ ហើយចំពោះចម្លើយដែល [redacted] សុជាតិ បានឆ្លើយថាបានទំនាក់ទំនងជាមួយខ្លួនតាមទូរស័ព្ទមករហូតនោះគឺមិនពិតទេ ពីព្រោះថា[redacted] សុជាតិ គឺមិនដែលបានស្គាល់លេខទូរស័ព្ទរបស់ខ្លួនពីមុនមកនោះទេ។ ខ្លួនសុំឱ្យតុលាការជួយឆែកលេខទូរស័ព្ទ បើសិនខ្លួនមានទាក់ទងជាមួយ[redacted] សុជាតិ មែនសុំឱ្យតុលាការបាញ់ខ្លួនក្រវ៉ាត់ចោលចុះ បើសិនជាខ្លួនធ្វើអាក្រក់ដូចគេថាមែន ពីព្រោះតាំងពីខ្លួនរត់ឡានមក ខ្លួនមិនដែលប្រព្រឹត្តអំពើអញ្ចឹងទេ។ ខ្លួនសំណូមពរសុំឱ្យតុលាការស្វែងរកជនដែលបានប្រព្រឹត្តអំពើជាមួយ[redacted]សុជាតិ នោះពីព្រោះខ្លួនមិនបានប្រព្រឹត្តអំពើនោះជាមួយ [redacted]សុជាតិ ទេ។

-លោកមេធាវី [redacted] សំអាត បានធ្វើសេចក្តីសន្និដ្ឋានការពារជនជាប់ចោទឈ្មោះ[redacted] សុជាតិ ដោយផ្ទាល់មាត់ថា ផ្អែកតាមការសិក្សាសំណុំរឿង ក៏ដូចជាការសួរដេញដោលគឺឃើញថាកូនក្តីខ្លួនបានទទួលស្គាល់នូវកំហុសតាំងពីដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ រហូតមកទល់ពេលនេះ។ ការទទួលស្គាល់កំហុសរបស់គាត់ គឺគាត់បានចូលរួមក្នុងការផ្តល់យុត្តិធម៌ដល់ជនរងគ្រោះផងដែរ ហើយគាត់ក៏មាន

សោកស្តាយចំពោះអំពើដែលគាត់បានប្រព្រឹត្តខុសឆ្គង។ មូលហេតុដែលគាត់ប្តឹងសាទុក្ខមកទីនេះ គឺគាត់បានបញ្ជាក់ហើយថា គាត់មានបំណងចង់សុំឱ្យតុលាការផ្តល់នូវស្ថានសម្រាលទោសដល់គាត់ ដើម្បីមានឱកាសកែប្រែខ្លួនឡើងវិញ។ មួយទៀតគឺពាក់ព័ន្ធទៅនឹងសំណង គឺគាត់មិនមានលទ្ធភាពក្នុងការសងនោះទេ។ ហើយចំណុចមួយទៀតដែលគាត់បានប្តឹងដែរនោះគឺពាក់ព័ន្ធទៅនឹងឡានដែលជាកម្មសិទ្ធិរបស់គាត់ ដែលត្រូវតុលាការរឹបអូសដាក់ជាទ្រព្យសម្បត្តិរបស់រដ្ឋ។ អញ្ចឹងផ្អែកតាមការពិនិត្យភស្តុតាង និងសាកសួរដេញដោល ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិ បានពិនិត្យឃើញថា កូនក្តីរបស់ខ្លួន បានសហការល្អក្នុងការចូលរួមនីតិវិធីនៅគ្រប់ដំណាក់កាល គប្បីតុលាការផ្តល់ស្ថានសម្រាលទោស ផ្អែកតាមមាត្រា ៩៣ និងមាត្រា ៩៥ នៃក្រមព្រហ្មទណ្ឌ។ ចំណុចទី២ គឺពាក់ព័ន្ធទៅនឹងការរឹបអូសរថយន្តដែលជាកម្មសិទ្ធិរបស់គាត់ តាមមាត្រា ៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌនោះ គឺអាចមានការភ័ន្តច្រលំ ដោយសារតែការរឹបអូសទ្រព្យសម្បត្តិជនល្មើស លុះត្រាតែជាផលប្រយោជន៍ ដែលបានមកពីការលាងលុយកង្វក់ និងបទល្មើសខុសច្បាប់ផ្សេងៗទៀត ដូចជាគ្រឿងញៀន ដែលអាចក្លាយជាកម្មវត្ថុក្នុងការរឹបអូសធ្វើជាទ្រព្យសម្បត្តិរដ្ឋបាន ប៉ុន្តែនេះរថយន្ត និងទូរស័ព្ទ ដែលជាកម្មសិទ្ធិរបស់កូនក្តីខ្លួន ត្រូវបានតុលាការរឹបអូសធ្វើជាទ្រព្យសម្បត្តិរដ្ឋដែរ។ ហេតុនេះក្នុងនាមខ្លួនជាមេធាវី ស្នើសុំឱ្យតុលាការមេត្តាពិចារណា ត្រង់ចំណុចនៃការរឹបអូសធ្វើជាទ្រព្យសម្បត្តិរដ្ឋ។

-លោកមេធាវី [redacted] សម្បត្តិ បានធ្វើសេចក្តីសន្និដ្ឋានការពារជនជាប់ចោទឈ្មោះ[redacted] សូនី ដោយផ្ទាល់មាត់ថាក្នុងរឿងក្តីនេះ ខ្លួនសូមបញ្ជាក់ថា ការបាត់បង់ជនរងគ្រោះ គឺពិតជារឿងមួយដ៏សោកសង្រេងមួយ ដែលជាការពិត យើងត្រូវផ្តល់នូវសេចក្តីអាណិតដល់ជនរងគ្រោះដែលមិនបានដឹងអីសោះ ហើយត្រូវរងគ្រោះនូវអំពើរំលោភសេពសន្ថវៈរហូតដល់សម្លាប់ ក៏ប៉ុន្តែទន្ទឹមនឹងនេះ ការសម្រេចផ្តន្ទាទោសកូនក្តីរបស់ខ្លួនដាក់ពន្ធនាគារអស់មួយជីវិត ខ្លួនយល់ឃើញថាក៏ជារឿងសោកសង្រេងមួយដែរ។ ប្រសិនបើមិនមានភស្តុតាងច្បាស់លាស់ និងមូលហេតុគ្រប់គ្រាន់ដែលអាចទទួលយកបាន ហើយបន្ទយកមនុស្សម្នាក់ទៅដាក់ពន្ធនាគារអស់មួយជីវិតដោយខ្លួនគេមិនបានប្រព្រឹត្តសោះ នោះគឺជារឿងមួយដ៏មហាសោកសង្រេងបំផុត។ ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិ ខ្លួនសុំលើកនូវចំណុចសំខាន់ ៤ ទៅ ៥ ចំណុចជូនលោកជំទាវប្រធានក្រុមប្រឹក្សា មេត្តាពិចារណា ដោយសាររឿងនេះខ្លួនយល់ឃើញថានៅមានចំណុចខ្វះខាតជាច្រើនដែលតុលាការថ្នាក់ក្រោមជាពិសេសសាលាដំបូងខេត្តស្វាយរៀង ក៏ដូចជាសាលាឧទ្ធរណ៍ភ្នំពេញមិនទាន់បានអនុវត្ត និងបំពេញដែលអាចឱ្យមានភាពជឿជាក់ថាកូនក្តីខ្លួនអាចជាប់គុកដោយអស់ចិត្[illegible] ចំណុចទាំងអស់នេះ ខ្លួនសុំលើកជូនក្រុមប្រឹក្សាជំនុំជម្រះមេត្តាពិចារណា។ នាពេលសវនាការមុន[illegible] លោកជំទាវបានសាកសួរចម្លើយទៅឈ្មោ[redacted]សុជាតិ ខ្លួនសុំបញ្ជាក់ជូនលោកជំទាវ និងក្រុមប្រឹក្សា[illegible] ជ្រាបថា ខ្លួនបានការពារក្នុងរឿងក្តីនេះចំនួន ៣សាលាក្តីហើយ ចម្លើយរបស[redacted]សុជាតិ ដែល[illegible]ឆ្លើយ



Scanned with CamScanner

នៅពេលសវនាការទាំងបីថ្នាក់ រួមទាំងចម្លើយរបស់[redacted]សុជាតិ ដែលបានឆ្លើយនៅចំពោះមុខសមត្ថកិច្ច ក៏ដូចជាចំពោះមុខព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរ គឺគាត់ព្យាយាមផ្លាស់ប្តូរចម្លើយ និងទម្លាក់កំហុសម្តងបន្តិចៗរហូតដល់ចុងក្រោយនេះ វាក្លាយទៅជាកូនក្តីខ្លួនឈ្មោ[redacted] សូនី មិនត្រឹមតែជាអ្នកចូលរួមទេ វាទៅជាអ្នកប្រព្រឹត្តដោយផ្ទាល់ទៅវិញ ដែលគប្បីលោកជំទាវ និងក្រុមប្រឹក្សាមេត្តាពិចារណា។ ចំណុចទាំងអស់នេះ ខ្លួនកត់សម្គាល់ឃើញថា ការទម្លាក់កំហុសមកលើ[redacted]សូនី គឺជាការបង្វែការយកចិត្តទុកដាក់ចំពោះជនល្មើសផ្សេងទៀត ដែលជាគូរកនសហការជាមួយ[redacted]សុជាតិ នេះជាចំណុចដែលខ្លួនស្នើសុំឱ្យលោកជំទាវពិចារណា។ ខ្លួនសុំលើកនៅចំណុចសំខាន់ៗមួយចំនួន គឺទីមួយ តាមចម្លើយរប[redacted]សុជាតិ ដែលបានឆ្លើយតាំងពីដើមរហូតមកដល់ថ្ងៃនេះ សុំឱ្យលោកជំទាវ និងក្រុមប្រឹក្សាមេត្តាពិចារណា ថាតើមនុស្សពីរនាក់ ដែលចូលរួមប្រព្រឹត្តបទល្មើស រំលោភសម្លាប់ ដោយមិនមានផែនការអ្វីសោះ តើអាចធ្វើទៅបានដែរឬទេ? តើដោយគ្រាន់តែ [redacted]សុជាតិ បានបើកឡានទៅជួបគ្នាជាមួយកូនក្តីខ្លួននៅអ្នកលឿង ហើយបានបើកកញ្ចក់និយាយគ្នាថាមានស្រីស្អាតអត់ តើនេះអាចជាផែនការឈានដល់ការរំលោភសម្លាប់គេដែរឬអត់? ហើយនេះគឺចំណុចមួយគួរឱ្យពិចារណាខ្លាំងមែនទែន។[redacted]សុជាតិ បានឆ្លើយថាគាត់បានមានទំនាក់ទំនងជាមួយកូនក្តីខ្លួនតាមផ្លូវរហូត សំនួរសួរថា តើទំនាក់ទំនងបែបណា បើនៅក្នុងឡានរៀងៗខ្លួនសិតតែមនុស្ស? ហើយនិយាយគ្នាពីផែនការរំលោភសម្លាប់បានយ៉ាងម៉េច? វាមិនបែកការទៅហើយឬ នេះជាចំណុចមួយ ដែលខ្លួនពិចារណាឃើញថា វាមិនអាចថាអត់មានផែនការសោះ ហើយបែរជាទៅរំលោភសម្លាប់គេកើតនោះទេ។ ចំពោះលេខទូរស័[redacted]សុជាតិ ថាបានទំនាក់ទំនងតាមទូរស័ព្ទ ហើយសមត្ថកិច្ច ក៏ដូចជាតុលាការថ្នាក់ក្រោម មិនបានធ្វើការបញ្ជាក់ឱ្យបានច្បាស់លាស់អំពីលេខទូរស័ព្ទនោះទាល់តែសោះ។ នៅក្នុងសំណុំរឿង ទាំងមូលខ្លួនយល់ឃើញថាមានតែចម្លើយរប[redacted]សុជាតិ តែម្នាក់គត់ដែលបានឆ្លើយដាក់បន្ទុកមកលើកូនក្តីខ្លួន ប៉ុន្តែសមត្ថកិច្ច មិនបានរកភស្តុតាងណាមួយឱ្យច្បាស់លាស់ដែលអាចឱ្យជឿជាក់បានថាកូនក្តីខ្លួនបានប្រព្រឹត្តនោះទេ។ ហើយនៅតុលាការថ្នាក់ក្រោម ខ្លួនក៏បានសុំឱ្យតុលាការយកទូរស័ព្ទដែលដកហូតបាននោះ មកឆែករកទន្និន័យនៃការទំនាក់ទំនងនោះដែរ ក៏ប៉ុន្តែតុលាការថ្នាក់ក្រោម មិនបានយកទូរស័ព្ទមកឆែកបង្ហាញនាពេលសវនាការនោះទេ ដែលនេះជាចំណុចខ្វះខាតមួយ ហើយជាចំណុចសំខាន់សុំឱ្យក្រុមប្រឹក្សាមេត្តាពិចារណា។ មុនេ[redacted]សុជាតិ បានឆ្លើយបញ្ជាក់យ៉ាងច្បាស់ជូនលោកជំទាវ និងក្រុមប្រឹក្សាថា គាត់បានធ្លាប់រួមគ្នាប្រព្រឹត្តបទល្មើសរំលោភជនជាតិវៀតណាម កាលពីយូរមកហើយ។ ខ្លួនជឿជាក់ថាឈ្មោ[redacted] សុជាតិ ឆ្លើយបែបនេះគឺដើម្បីឱ្យតុលាការជឿថា ចម្លើយរបស់គាត់នៅពេលនេះគឺត្រឹមត្រូវ និងជាការពិត ពីព្រោះថាពួកគេធ្លាប់បានប្រព្រឹត្តម្តងរួចហើយ ដូច្នេះហើយគឺយល់គ្នាហើយ ស្គាល់កន្លែងណាត់គ្នាហើយ ស្គាល់ផែនការរបៀបរំលោភសម្លាប់ហើយ [illegible] ទាំងនេះគឺគាត់ចង់ឱ្យតុលាការជឿគាត់។ ហើយចំណុចទាំងអស់នេះ គឺខ្លួនបានសុំឱ្យ[illegible]

នៅសាលាដំបូងខេត្តស្វាយរៀង បើយោងតាមចម្លើយរបស់គាត់ដែលបានឆ្លើយនៅដំណាក់អយ្យការគឺនៅថ្ងៃទី ២០ ខែមេសា ឆ្នាំ២០១៧ ថា "ពួកខ្ញុំបានធ្វើសកម្មភាពម្តងហើយជាមួយ[redacted]សូនី ដែលលោកស្រីជនជាតិវៀតណាម"។ ហើយចំណុចទាំងអស់នេះ ខ្លួនបានស្នើសុំឱ្យសាលាដំបូងខេត្តស្វាយរៀង ធ្វើការចាត់របៀប និងចុះស៊ើបអង្កេត រកថាតើមានសំណុំរឿងនៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៧ ដែរឬអត់? ប៉ុន្តែតុលាការខេត្តស្វាយរៀង មិនធ្វើអ្វីទាំងអស់។ ដូច្នេះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិ និងប្រយោជន៍ច្បាប់ ខ្លួនបញ្ជាក់សរុបចុងក្រោយថាទី១ ចំណុចទូរស័ព្ទ ដែលគប្បីតុលាការធ្វើការបញ្ជាក់ឡើងវិញ។ ទី២ ចំណុចបទល្មើសកើតឡើងនៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៧ ដែលជាចំណុចសំខាន់ សុំឱ្យតុលាការបញ្ជាក់ឱ្យច្បាស់លាស់ថាមានអង្គហេតុនោះកើតឡើងដែរឬទេ។ ហើយចំណុចមួយទៀត ពាក់ព័ន្ធនឹងចម្លើយរបស់[redacted] ផាន់នី ខ្លួនសុំលើកជូនលោកជំទាវ ដើម្បីពិចារណា ពីព្រោះវាមានប្រយោជន៍នៃភាពយុត្តិធម៌របស់កូនក្តីខ្លួន។ ដូច្នេះចំណុចទាំងអស់នេះខ្លួនសុំដាក់ជូនលោកជំទាវ និងក្រុមប្រឹក្សាមេត្តាពិនិត្យ ពិចារណា និងសម្រេចបដិសេធសាលដីលេខ ២៨ ក្រVសស ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ និងបង្វិលសំណុំរឿងនេះឱ្យសាលាឧទ្ធរណ៍ធ្វើការអង្កេត និងពិនិត្យឡើងវិញ លើចំណុចទូរស័ព្ទ លើចំណុចសំណុំរឿងថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៧ លើចម្លើយរបស់[redacted]ផាន់នី និងចម្លើយរបស់សាក្សីទាំងអស់ ដែលបានបញ្ជាក់ថាកូនក្តីខ្លួនមិនបាននៅនឹងកន្លែងកើតហេតុ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ស្រីឡូត បានឆ្លើយថានៅថ្ងៃកើតហេតុកូនខ្លួនបានធ្វើដំណើរចេញពីផ្ទះនៅព្រះវិហា ទៅបាវិត ហើយខ្លួនបានទាក់ទងសួរកូនមករហូត ហើយនៅប្រហែលម៉ោង ៥ ទៅ ៦ល្ងាច កូនខ្លួនបានប្រាប់ខ្លួនថា "ម៉ាក់អើយកូនមកដល់ហើយ ប៉ុន្តែតៃកុងឡានមិនទាន់ដាក់ខ្ញុំចុះទេ តៃកុងឡានថាចូលទៅផ្លូវលំយកភ្ញៀវម្នាក់ទៀត ហើយកូនថាចាំ១០នាទីទៀត ចាំកូនតេទៅម្តងទៀត"។ លុះក្រោយមកប្រហែលជាកន្លះម៉ោង មិនឃើញកូនតេមក ខ្លួនក៏តេទៅកូនវិញ ប៉ុន្តែគ្មានអ្នកណាលើកទូរស័ព្ទទេ ហើយឆាតក៏ឆាតមិនតបដែរ។ ខ្លួនក៏មានចិត្តសង្ស័យ ខ្លួនក៏បានធ្វើដំណើរចេញពីព្រះវិហាទាំងយប់ មកខេត្តស្វាយរៀង ហើយក៏បានដាក់ពាក្យបណ្តឹងទាំងយប់ ក្រោយពីខ្លួនបានដាក់ពាក្យបណ្តឹងរួចមក ខាងសមត្ថកិច្ចក៏បានចុះស្រាវជ្រាវអស់រយៈពេល ២ថ្ងៃ ទើបបានឱ្យដំណឹងមកខ្លួនថាមកមើលសាកសព ហើយក៏បានហៅក្រុមគ្រួសារខ្លួនទៅមើល ឃើញថាពិតជាកូនស្រីរបស់ខ្លួនមែន។ ខ្លួនសុំសំណូមពរតុលាការដាក់ទោសឃាតកទាំងពីរនាក់នោះតាមច្បាប់ ព្រមទាំងឱ្យរួមគ្នាសងសំណងមកខ្លួនផង។ ចំពោះឡាន ហាយឡែនឌ័រ ដែលរឹបអូសជាទ្រព្យសម្បត្តិ ខ្លួនសុំឱ្យដកយកមកលក់ឡៃឡុង ដើម្បីធ្វើជាប្រាក់សំណងមកខ្លួនវិញ។



Scanned with CamScanner

-លោកស្រី [redacted] ស៊ីណាកេត បានធ្វើសេចក្ដីសន្និដ្ឋានការពារឱ្យដើមបណ្ដឹងរដ្ឋប្បវេណី ដោយផ្ទាល់មាត់ថា ក្រោយពីបានសិក្សាលើសំណុំរឿង និងស្ដាប់ការសួរដេញដោលនាពេលសវនាការនេះ ឃើញថាជនជាប់ចោទ [redacted] សុជាតិ បានឆ្លើយសារភាពថាគាត់ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ពិតប្រាកដមែន ប៉ុន្តែចំពោះជនជាប់ចោទ [redacted] សូនី គាត់បានឆ្លើយបដិសេធថាគាត់មិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ។ បើយើងពិនិត្យលើអង្គហេតុ ការលើករបស់ [redacted] សុជាតិ គឺមានភាពស៊ីសង្វាក់គ្នាជាមួយចម្លើយរបស់ដើមបណ្ដឹង [redacted] ស្រីឡូត និងសាក្សីឈ្មោះ [redacted] ចន្ធូ ។ ដូចដែលលោកជំទាវបានដឹងរួចហើយថាជនល្មើសតែម្នាក់គឺមិនអាចប្រព្រឹត្តបទល្មើសបានទេ គឺដល់តែមានពីរនាក់។ ចំពោះចម្លើយរបស់ [redacted] សុជាតិ បានឆ្លើយនាពេលសវនាការគឺថាពេលមកដល់ចំណុចមន្ទីរពេទ្យជីកូគឺ [redacted] សូនី បានឡើងលើឡានគាត់ ហើយថាបានជិះចុះទៅផ្លូវលំ ដើម្បីទៅយកម៉ូយម្នាក់ទៀត ហើយបើយើងពិនិត្យចម្លើយរបស់ដើមបណ្ដឹង និងចម្លើយរបស់ [redacted] ន្ធូ ដែលគាត់ថាគាត់បានតេសួរកូនគាត់នៅចន្លោះម៉ោង ៥ ទៅ ៦ ល្ងាចហ្នឹងគឺកូនគាត់បានប្រាប់គាត់ថា កូនគាត់មកដល់ផ្សារជីកូហើយ អ្នករត់តាក់ស៊ីប្រាប់កូនគាត់ថា ចុះទៅតាមផ្លូវលំ ហើយកូនគាត់ប្រាប់ថាមិនស្គាល់ទេ។ ចំណុចទាំងនេះគឺមានភាពស៊ីសង្វាក់គ្នាខ្លាំងណាស់ មានន័យថាជនជាប់ចោទឈ្មោះ [redacted] សុជាតិ ពិតជាបានឈប់ឡាន ដើម្បីយកជនជាប់ចោទម្នាក់ទៀត ឈ្មោះ [redacted] សូនី ដើម្បីទៅធ្វើសកម្មភាពរួមជាមួយគ្នាពិតមែន។ ដូច្នេះនៅក្នុងរឿងក្ដីនេះខ្លួនជាមេធាវីការពារឱ្យដើមបណ្ដឹង ស្នើសុំឱ្យលោកជំទាវប្រធាន មេត្តាសម្រេចផ្ដន្ទាទោសជនល្មើសទាំងពីរនាក់នេះឱ្យបានធ្ងន់ធ្ងរ ពីព្រោះពួកគាត់បានប្រព្រឹត្តអំពើឃោរឃៅទៅលើជនរងគ្រោះ ហើយបើយើងពិនិត្យលើមាត្រា ២០៥ វិញ ឃើញថាការផ្ដន្ទាទោសទៅលើជនល្មើស គឺសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ដែលចំណុចនេះខ្លួនសំណូមពរសុំឱ្យលោកជំទាវ មិនគួរគេប្បីសម្រេចពិចារណាស្ថានសម្រាលចំពោះគាត់នោះទេ។ ពាក់ព័ន្ធទៅនឹងសំណង សុំឱ្យលោកជំទាវ សម្រេចតាមការទាមទាររបស់កូនក្ដីខ្លួន ចំនួន ៦ម៉ឺន ដុល្លារ ហើយដូចដែលកូនក្ដីខ្លួន បានលើកឡើងហើយថាចំពោះរថយន្តហាយលែនឌ័រ សុំឱ្យលោកជំទាវសម្រេចលក់ឡៃឡុងឡាននោះ ដើម្បីសំណងមកកូនក្ដីរបស់ខ្លួន ពីព្រោះថាតាំងពីតុលាការសម្រេចឱ្យសងសំណងមកគាត់គឺមិនទាន់ទទួលបានសំណងនោះទេ។

- ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទទាំងពីរនាក់ និងដើមបណ្ដឹងរដ្ឋប្បវេណី
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីគូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ



Scanned with CamScanner

# សំអាងហេតុ

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៨២ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] សូនី និងបណ្តឹងសាទុក្ខលេខ ៨៥ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] សុជាតិ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបាន តាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-យល់ឃើញថា ការដែលជនជាប់ចោទឈ្មោះ [redacted] សុជាតិ ប្តឹងសាទុក្ខមកនេះគឺសុំឱ្យតុលាការកំពូលបន្ធូរបន្ថយទោស ព្រមទាំងសុំបន្ធូរបន្ថយសំណងជួសជុលការខូចខាត និងជម្ងឺចិត្តដែលសាលាឧទ្ធរណ៍បានសម្រេចតែប៉ុណ្ណោះ។ ចំពោះសកម្មភាពប្រព្រឹត្តទាំងប៉ុន្មានជនជាប់ចោទនៅតែសារភាពទទួលស្គាល់កំហុសទាំងអស់ មិនមានការកែប្រែទេ។

តុលាការកំពូលពិនិត្យឃើញថា បទល្មើសនេះជាបទឧក្រិដ្ឋធ្ងន់ធ្ងរ ធ្វើឱ្យបាត់បង់អាយុជីវិតនារីវ័យក្មេងម្នាក់ ធ្វើឱ្យប៉ះពាល់ខ្លាំងដល់ទំនៀមទម្លាប់ប្រពៃណីរបស់ប្រជនខ្មែរ ធ្វើឱ្យសង្គមមានការភ្ញាក់ផ្អើល។ អំពើរបស់ជនជាប់ចោទរូបនេះ ត្រូវបានសាលាឧទ្ធរណ៍បដិសេធមិនផ្តល់ស្ថានសម្រាល ដែលកំណត់ក្នុងមាត្រា ៩៣ នៃក្រមព្រហ្មទណ្ឌទេ។ តុលាការកំពូលពិនិត្យលើលក្ខណៈធ្ងន់ធ្ងរនៃអំពើល្មើសនេះ ហើយឯកភាពមិនផ្តល់អត្ថប្រយោជន៍នៃគោលការណ៍ស្ថានសម្រាលដល់ជនជាប់ចោទនេះទេ។

ចំពោះសំណងជួសជុលការខូចខាត និងជម្ងឺចិត្ត ក៏តុលាការកំពូលយល់ឃើញថាការបាត់បង់អាយុជីវិតកូនស្រីតែមួយ ដោយត្រូវរំលោភសេពសន្ថវៈ ហើយសម្លាប់ដូចសត្វធាតុគឺជាការធ្ងន់ធ្ងរណាស់ហើយ។ ដូច្នេះមិនទទួលពិចារណាចំណុចនេះទៀតទេ។

៣-យល់ឃើញថា ការដែលជនជាប់ចោទឈ្មោះ [redacted] សូនី នៅតែឆ្លើយបដិសេធថាខ្លួនមិនបានចូលរួមប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ទេ -ថានៅថ្ងៃកើតហេតុខ្លួនមិនបានទាក់ទងជាមួយ [redacted] សុជាតិ ទេ -ថាបន្ទាប់ពីជាក់គុ កៅអីឱ្យភ្ញៀវរួចខ្លួនបានចូលផ្ទះលាងឡាន ហើយមិនបានចេញទៅណាទៀតទេ -ថាខ្លួនមានទំនាស់ជាមួយ [redacted] សុជាតិ ។ ថាការដែល [redacted] សុជាតិ ឆ្លើយដាក់បន្ទុកលើខ្លួនមក [redacted] សុជាតិ ចង់លាក់ជនម្នាក់ទៀតដែលបានចូលរួមសកម្មភាពនេះ ហើយ [redacted] សុជាតិ ស្ទប់ខ្លួននោះ។

តុលាការកំពូលពិនិត្យឃើញថា ចម្លើយរបស់ [redacted] សុជាតិ ចាប់តាំងពីពេលត្រូវសមត្ថកិច្ចឃាត់ខ្លួនភ្លាម រហូតដល់តុលាការគ្រប់ថ្នាក់ ជាចម្លើយឥតប្រែប្រួល ហើយមានភាពស៊ីសង្វាក់គ្នាទៅនឹងអង្គហេតុនៃរឿងក្តីនេះ។ ជាការពិត [redacted] សុជាតិ គ្មានប្រយោជន៍អ្វីដែលត្រូវឆ្លើយដាក់បន្ទុកលើ [redacted] សូនី ទេ បើប្រសិនមិនបានចូលរួមប្រព្រឹត្តជាមួយទេនោះ។ អំពើល្មើសនេះ មិនអាចធ្វើទៅបានទេ បើមានមនុស្សតែម្នាក់ ហេតុនេះត្រូវការជនទីពីរ គឺ [redacted] សូនី ។ [redacted] សុជាតិ កំពុងបើករថយ [redacted] សូនី ជាអ្នកប្រើហិង្សារួចរំលោភសេពសន្ថវៈនារីរងគ្រោះ ហើយបន្ទាប់មកទៀត [redacted] សុជាតិ រំលោភម្តង មុននឹងសម្លាប់នារីរងគ្រោះ។ ក្នុងភាពជាក់



Scanned with CamScanner

បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] សុនី ធួនល្មមអាចឱ្យជឿថា ជនជាប់ចោទរូបនេះ ពិតជាបានចូលរួមក្នុងអំពើរំលោភសេពសន្ថវៈ និងឃាតកម្មដោយមានទារុណកម្មលើនារីរងគ្រោះ [redacted] សុម៉ាលីន កាលពីថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៧ នៅភូមិតាពៅ សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសដោយមាត្រា ២០៥ នៃក្រមព្រហ្មទណ្ឌ។

៤-យល់ឃើញថា ការដែលតុលាការអង្គសេចក្តីសម្រេចថា រថយន្តម៉ាកហាយលែនឌ័រពណ៌ស ពាក់ស្លាកលេខ 2AQ-0525 ត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ ដោយគ្មានសំអាងហេតុនោះ។

តុលាការកំពូលពិនិត្យឃើញថា ចំណុចនេះជាការមិនត្រឹមត្រូវទេ លើការដែលសាលាឧទ្ធរណ៍ចាត់ទុកក្នុងឃ្លាចុងក្រោយនៃចំណុចទី១០ នៃសាលដីការបស់ខ្លួនថា " រថយន្តនេះជាវត្ថុតាង" គឺជាការភ័ន្តច្រឡំ រថយន្តនេះមិនត្រូវបានជនជាប់ចោទប្រើប្រាស់ជាឧបករណ៍ដើម្បីប្រព្រឹត្តបទល្មើសនេះទេ គ្រាន់តែបទល្មើសនេះកើតឡើងនៅក្នុងរថយន្តប៉ុណ្ណោះ ដូច្នេះរថយន្តនេះមិនមែនជាវត្ថុតាងនោះទេ។ ហេតុនេះតុលាការមិនអាចរឹបអូសរថយន្តនេះ ទុកជាសម្បត្តិរដ្ឋបានទេ។

៥-យល់ឃើញថា តុលាការអង្គសេចក្តីបានសម្រេចអំពីសំណងជួសជុលការខូចខាត និងជម្ងឺចិត្តដោយឱ្យជនជាប់ចោទទាំងពីររួមគ្នាសងចំនួន ៦០.០០០ ដុល្លារ ទៅដើមបណ្តឹងរដ្ឋប្បវេណីរួចហើយ ហើយនាពេលសវនាការនេះ ដើមបណ្តឹងរដ្ឋប្បវេណី ក៏បានសុំទាមទារឱ្យរឹបអូសរថយន្តខាងលើ ដើម្បីលក់ ទូទាត់សំណងខូចខាតផងនោះ។

តុលាការកំពូលយល់ឃើញថា ទោះជាយ៉ាងណាក៏ដោយ ក៏ពេលសេចក្តីសម្រេចរបស់តុលាការចូលជាស្ថាពរ មុខជានឹងមានការលក់ឡាយឡុងទ្រព្យរបស់ជនជាប់ចោទទាំងពីរដើម្បីអនុវត្ត ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីជាមិនខាន ហេតុនេះដើម្បីជៀសវាងការខាតពេលវេលា និងសោហ៊ុយសោដាផ្សេងៗ ហើយបើរក្សារថយន្តទុកយូរទៅនឹងនាំឱ្យថយតម្លៃរថយន្ត គប្បីតុលាការកំពូលអនុញ្ញាតឱ្យរឹបអូសរថយន្តលក់ឡាយឡុងយកប្រាក់បណ្តោះសងសំណងជួសជុលការខូចខាត និងជម្ងឺចិត្តដល់ដើមបណ្តឹង។

៦-យល់ឃើញថា សាលដីកាលេខ ២៨ ក្រVសស ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញត្រឹមត្រូវខ្លះ និងមិនត្រឹមត្រូវខ្លះនឹងគតិច្បាប់។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១-ទទួលបណ្តឹងសាទុក្ខលេខ ៨២ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] សុនី និងបណ្តឹងសាទុក្ខលេខ ៨៥ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] សុជាតិ។

២) តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ២៨ ក្រVសស ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញ លើកលែងតែចំណុចទី៣ ត្រង់ទី១ នៃសាលក្រមលេខ ២០០ (ឃ) ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តស្វាយរៀង ដែលត្រូវទុកជាមោឃៈ ហើយសម្រេចជាថ្មីថា "រថយន្តម៉ាកហាយឡែនឌ័រ ពាក់ស្លាកលេខភ្នំពេញ 2AQ-0525 ដែលបានដកហូតពីជនជាប់ចោទត្រូវរឹបអូសលក់ឡាយឡុង យកប្រាក់សងបណ្ដោះប្រាក់សំណងជួសជុលការខូចខាត និងជម្ងឺចិត្តទៅដើមបណ្ដឹងរដ្ឋប្បវេណី។

សាលដីកានេះជំនុំជម្រះនៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២១ និងប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១។

| | | |
|---|---|---|
| លោកជំទាវ | [redacted] | ជាប្រធាន |
| ឯកឧត្តម | [redacted] | ជាចៅក្រម |
| ឯកឧត្តម | [redacted] | ជាចៅក្រម |
| ឯកឧត្តម | [redacted] | ជាចៅក្រម |
| លោកជំទាវ | [redacted] | ជាចៅក្រម |
| លោក | [redacted] | ជាក្រឡាបញ្ជី |

---

**បានឃើញ**

ថ្ងៃចន្ទ ១រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានចម្លងត្រឹមត្រូវតាមសាលដីកាដើម។

ថ្ងៃចន្ទ ១រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១

ក្រឡាបញ្ជី

[redacted]